# MORDIALLOC COLLEGE
# (វិទ្យាល័យ ម័រឌីយលឡក)

## កម្មវិធីសិស្សអន្តរជាតិ

រដ្ឋវិចថូរៀ ប្រទេសអូស្ត្រាលី
ក្រសួងអប់រំ




VICTORIA
State Government
Australia



WE CREATE A SAFE, SOCIAL AND PHYSICAL ENVIRONMENT WHICH HELPS ALL OUR STUDENTS LEARN AND SUCCEED.

# សារពីនាយកសាលា

**វិទ្យាល័យ Mordialloc ជាសាលាសហគមន៍ប្រកបដោយមោទនភាព ដែលមានការប្តេជ្ញាធ្វើឱ្យសិស្សទទួលបានជោគជ័យ។**

វិទ្យាល័យរបស់យើងធ្វើបានល្អត្រចង់ក្នុងការផ្តល់ការអប់រំដែលមានគុណភាពខ្ពស់សម្រាប់រៀបចំសិស្សានុសិស្សរបស់យើងដើម្បីចូលរួមផ្តល់អ្វីដែលវិជ្ជមានដល់សហគមន៍សាលារបស់យើង និងលើសពីហ្នឹងទៀត។ យើងជឿថាវាជាការប្រសើរដែលក្នុងការបង្កឱ្យមានទំនាក់ទំនងរឹងមាំជាមួយគ្រួសារទាំងឡាយរបស់យើងនិងសហគមន៍របស់យើង ដោយមានការទទួលស្គាល់ថា ការអប់រំគឺលាតសន្ធឹងហួសពីការទទួលបានលទ្ធផលសិក្សាត្រចះត្រចង់ទៅទៀត។

នៅវិទ្យាល័យ Mordialloc យើងប្រកាន់យកគុណតម្លៃនៃការគោរពគ្នា សុច្ចរិតភាព ការធ្វើបានល្អបំផុតរបស់បុគ្គល ហើយនិងការទទួលខុសត្រូវ។ គុណតម្លៃអស់ទាំងនេះគឺកែតម្រង់កិរិយាមាយាទរបស់សិស្សានុសិស្សរបស់យើង និងរៀបចំពួកគេសម្រាប់អនាគតនៅក្រៅសាលារបស់យើង។

យើងផ្តល់អាទិភាពដល់របៀបនៃការបង្រៀននិងការរៀនដែលតម្រូវតាមបុគ្គលនីមួយៗ។ យើងដឹងថាការអប់រំដាយានាំឱ្យទៅដល់តពនៃឱកាសជាច្រើននិងលទ្ធភាពជាច្រើនសម្រាប់សិស្សានុសិស្សរបស់យើង។

កម្មវិធីសិក្សាដែលយើងបានរចនាឡើងប្រកបដោយការគិតយ៉ាងហ្មត់ចត់ គឺធ្វើឱ្យសិស្សគិតនិងមានចិត្តចង់ធ្វើកិច្ចការនានា ហើយក្រមលោកគ្រូអ្នកគ្រូប្រកបដោយការប្តេជ្ញាចិត្ត ព្រមទាំងបុគ្គលិករបស់យើងធ្វើការគ្មាននឿយហត់ក្នុងការជ្នាក់ថ្នមនិងបណ្តើនសក្តានុពលរបស់សិស្សនីមួយៗ គឺផ្តល់កម្មវិធីនិងសកម្មភាពជាច្រើនដែលរចនាឱ្យស្របតាមចំណង់ចំណូលចិត្តនិងសេចក្តីត្រូវការរបស់សិស្សនីមួយៗ។

នៅក្នុងលោកដែលមានការផ្លាស់ប្តូរមិនចេះចប់ដែលផ្តល់រង្វាន់ដល់ការព្យាយាម ការចេះមានគំនិតផ្តួចផ្តើម និងការចេះកែច្នៃ សិស្សានុសិស្សរបស់យើងចេញពីវិទ្យាល័យ Mordialloc ទៅប្រកបដោយការរៀបចំខ្លួនយ៉ាងពេញលេញសម្រាប់ភាពជោគជ័យក្នុងឧត្តមសិក្សា ការសិក្សាវិជ្ជាជីវៈ និងការធ្វើការងារ។

ខ្ញុំមានមោទនភាពណាស់ក្នុងការដឹកនាំសាលាដ៏អស្ចារ្យនេះ និងចំពោះសិស្សដ៏អស្ចារ្យទាំងឡាយដែលធ្វើឱ្យវិទ្យាល័យ Mordialloc ជាជម្រើសដែលប្រសើរជាងសាលាដទៃក្នុងវិស័យអប់រំ។

សូមអរគុណចំពោះការពិចារណាអំពីវិទ្យាល័យ Mordialloc សម្រាប់ការអប់រំកូនរបស់អ្នក។

**រ៉ែកឈល់ ស្តូន (Rachael Stone)**

**នាយកសាលា**



# ហេតុអ្វីជ្រើសយកវិទ្យាល័យ MORDIALLOC?

**កម្មវិធីសិស្សអន្តរជាតិរបស់យើង - ដែលជាផ្នែកមានតម្លៃមួយនៃសហគមន៍ពហុវប្បធម៌របស់សាលាយើង - បានស្វាគមន៍សិស្សពីទ្វីបអាស៊ីនិងអឺរ៉ុបជាហូរហែច្រើនឆ្នាំមកហើយ។**

កម្មវិធីនៅសាលាយើងដែលត្រូវបានរចនាពិសេសសម្រាប់សិស្សអន្តរជាតិ រួមមាន៖

- ក្រុមការងារមួយដែលមានភារកិច្ចតែខាងសិស្សអន្តរជាតិ
- មណ្ឌលភាសាអង់គ្លេសប្រកបដោយថ្នាក់តូចៗនៅនឹងកន្លែង
- ជំនួយបន្ថែមខាង English as an Additional Language (EAL) (ភាសាអង់គ្លេសជាភាសាបន្ថែម) និងគណិតវិទ្យា
- មណ្ឌលខាងវិស័យអាជីពយ៉ាងល្អដែលផ្តល់ឱកាទជាច្រើនខាងជម្រើសផ្លូវសម្រាប់ការសិក្សានិងអាជីព
- កម្មវិធីជំនាញក្នុងការសិក្សាដែលប្រព្រឹត្តទៅពេញឆ្នាំទាំងមូលសម្រាប់ថ្នាក់គ្រប់កម្រិត
- ការផ្តល់រយៈពេលជំនួយក្រោយម៉ោងសាលារៀងរាល់សប្តាហ៍
- អ្នកសម្របសម្រួលអ្នកស្នាក់នៅតាមផ្ទះ (homestay) ដែលធ្វើការយ៉ាងជិតជិតជាមួយគ្រួសារ homestay ទាំងឡាយប្រកបដោយបទពិសោធន៍របស់យើង ដែលជួយក្នុងអន្តរកាលនៃការចូលទៅក្នុងសហគមន៍សាលា។

## ល្អអស្ចារ្យណាស់ខាងផ្នែកសិក្សាក្នុងថ្នាក់

នៅវិទ្យាល័យ Mordialloc យើងមានមោទនភាពចំពោះកំណត់ត្រារបស់យើងក្នុងការបង្កើតបានសិស្សទាំងឡាយដែលពូកែយ៉ាងលេចធ្លោ។ ក្នុងឆ្នាំថ្មីៗកន្លងមក សិស្សអន្តរជាតិនានារបស់យើងទទួលបានលទ្ធផលគួរជាទីគាប់ចិត្តណាស់នៅថ្នាក់ទី 12។ កន្លែងទទួលឱ្យចូលក្នុងឧត្តមសិក្សារួមមានសាកលវិទ្យាល័យ Melbourne និង Monash ក្នុងវិស័យ វិទ្យាសាស្ត្រ សិល្បៈ វិស្វកម្ម ពាណិជ្ជកម្ម វេជ្ជសាស្ត្រ ច្បាប់ ព័ត៌មានវិទ្យា និងជំនួញ។

នៅថ្នាក់ទាប។ សិស្សរបស់យើងប្រយុទ្ធក្នុងកម្មវិធីសិក្សាមុខវិជ្ជាស្នូលរួមមាន ភាសាអង់គ្លេស គណិតវិទ្យា និងវិទ្យាសាស្ត្រ ផ្គួបជាមួយមុខវិជ្ជាតាមការជ្រើសរើស ដូចជាសិល្បៈ បច្ចេកវិទ្យាខាងអាហារ និងសិល្បៈរណ្តាន។

ពេលពួកគេឆ្លងទៅថ្នាក់ទី 11 និងទី 12 សិស្សនានាចុះឈ្មោះរៀនយក Victorian Certificate of Education (VCE) (វិញ្ញាបនបត្រសិក្សានៅវិចថូរៀ) និងមានមុខវិជ្ជាជាច្រើនសម្រាប់ជ្រើសយក។ ការទទួលបានសញ្ញាបត្រ VCE ធ្វើឱ្យសិស្សអាចសិក្សានៅសាកលវិទ្យាល័យនានានៅរដ្ឋវិចថូរៀនិងរដ្ឋដទៃទៀតនៅប្រទេសអូស្ត្រាលី។

សិស្សអន្តរជាតិនានារបស់យើងជាសមាជិកប្រកបដោយមោទនភាពនៃសហគមន៍របស់យើង និងអោបក្រសោបរបៀបរស់នៅនិងវប្បធម៌អូស្ត្រាលី។ ពួកគេបង្កើនជានិច្ចជំនាញភាសាអង់គ្លេសដើម្បីបង្កើតបានមិត្តភក្តិថ្មីៗ និងចូលរួមជាមួយមិត្តរួមថ្នាក់របស់ពួកគេនៅក្នុងកម្មវិធីនៃការទៅកន្លែងបោះជំរុំ ធ្វើដំណើរទៅទស្សនាជាក្រុម កីឡាតន្ត្រី និងសិល្បៈសំដែងនានានៅក្នុងវិទ្យាល័យនេះ។





## សកម្មភាពក្រៅកម្មវិធីសិក្សាដើម្បីបង្កើនបទពិសោធន៍របស់សិស្សឱ្យកាន់តែសម្បូរបែប

យើងជឿលើការធ្វើឱ្យទេពកោសល្យនិងចំណង់ចំណូលចិត្តរបស់សិស្សមានភាពរស់រវើក។ យើងមានផ្តល់កម្មវិធីដ៏សំបូរបែបនៃសកម្មភាពក្រៅកម្មវិធីសិក្សាពេញទូទាំងមួយឆ្នាំ។

កម្មវិធីក្រៅកម្មវិធីសិក្សាទាំងឡាយគឺមានទំនាក់ទំនងយ៉ាងជិតជាមួយកម្មវិធីសិក្សា។ កម្មវិធីទាំងនេះជួយសិស្សក្នុងការបណ្តុះការយល់ដឹងកាន់តែជ្រៅ ហើយនិងទទួលបានបទពិសោធន៍តាមការធ្វើផ្ទាល់ក្នុងវិស័យដែលខ្លួនមានចំណង់ចំណូលចិត្ត។

សកម្មភាពទាំងឡាយនៅ Mordialloc រួមមាន៖

- ព្រឹត្តការណ៍ពិសេស និងដំណើរកំសាន្តជាក្រុមសម្រាប់សិស្សអន្តរជាតិ
- ការបោះជំរុំនិងដំណើរកំសាន្តជាច្រើនប្រភេទសម្រាប់មុខវិជ្ជាអ្វីមួយជាក់លាក់
- កម្មវិធីតន្ត្រីនិងសិល្បៈ:សំដែងរួមទាំងការប្រគំតន្ត្រីនានានិងការប្រគំភ្លេងប្រចាំឆ្នាំរបស់សាលា។
- ការតាំងពិពណ៌សិល្បៈសាលា
- ឱកាសដឹកនាំរបស់សិស្សនៅគ្រប់កម្រិតថ្នាក់
- សកម្មភាពនាពេលអាហារថ្ងៃត្រង់រួមមាន ក្លឹបចតុរង្គ ក្លឹបរៀនលេខកូដ ការជជែកដែកញែក ក្លឹបភាសា ហើយនិងសកម្មភាពកីឡា។

## ពេលណាសុខុមាលភាពរបស់សិស្សជាអាទិភាព

នៅវិទ្យាល័យ Mordialloc យើងទទួលស្គាល់ថា សុខុមាលភាពរបស់សិស្សយើងគឺសំខាន់ដូចលទ្ធផលសិក្សារបស់ពួកគេដែរ។

ក្រុមអ្នកសម្របសម្រួលសិស្សអន្តរជាតិដែលប្រកបដោយការប្តេជ្ញាចិត្ត មើលថែសិស្សរបស់យើងដោយមានជំនួយបន្ថែម រួមទាំង៖

កម្មវិធីណែនាំផ្លូវដោយលម្អិត

គ្រូពេទ្យខាងសុភាពផ្លូវចិត្តម្នាក់

អ្នកជំនាញខាងមនុស្សវ័យជំទង់ម្នាក់

គ្រូពេទ្យខាងការនិយាយម្នាក់

គិលានុបដ្ឋាយិកាប្រចាំសាលាមធ្យមសិក្សាម្នាក់

បុគ្គលិកសាលាដែលចេះភាសាជប៉ុន វៀតណាម ចិន (កុកងឺ និង កន្តាំង) កូរ៉េ ឥណ្ឌូនេស៊ី និងបារាំង ដើម្បីជួយសិស្សយើង

គំនិតផ្តួចផ្តើមជួយមិត្ត និងកម្មវិធីឱ្យមានគូកននៅជិតសម្រាប់សិស្សក្នុងស្រុកនិងអន្តរជាតិ។

## ការស្នាក់នៅតាមផ្ទះ (Homestay) សម្រាប់សិស្សអន្តរជាតិ

គ្រួសារដែលជាម្ចាស់ផ្ទះ Homestay មានតួនាទីសំខាន់ណាស់ក្នុងសហគមន៍សាលារបស់យើង។ គ្រួសារដែលជាម្ចាស់ផ្ទះទាំងអស់របស់យើងត្រូវបានជ្រើសរើសផ្អែកតាមបទពិសោធន៍របស់ពួកគេក្នុងការថែទាំសិស្សនិងស្វាគមន៍សិស្សមកកាន់ផ្ទះរបស់ខ្លួន។

នៅរដ្ឋវិចថូរៀ ចំពោះសាលារៀនរដ្ឋ គ្រប់គ្រួសារដែលផ្តល់ការស្នាក់នៅតាមផ្ទះទាំងអស់មានផ្តល់នូវ៖

កន្លែងមួយដែលមានសុវត្ថិភាព មានសន្តិសុខ និងមានការស្វាគមន៍សម្រាប់ការរស់នៅ

ផ្ទះគ្រួសារដែលត្រូវតាមស្តង់ដាសុវត្ថិភាពកុមារ

បន្ទប់មួយដោយឡែកសម្រាប់សិស្សនោះប្រើម្នាក់ឯង

អាហារបីពេលក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ រួមទាំងអាហារសម្រន់ផងដែរ

សម្ភារៈផ្សេងៗដូចជាគ្រែ ទូរដាក់សម្លៀកបំពាក់ កន្សែងនិងកម្រាលពូក

គ្រឿងសម្ភារៈប្រើប្រាស់រួមទាំង ហ្គាស អគ្គិសនី ការកម្តៅ និងថ្លៃទឹកនិងអ៊ីនធឺណិត

សេវាសម្អាតកន្លែងរស់នៅរួម

ការប្រើប្រាស់កន្លែងសាឡុងក្នុងគេហដ្ឋាន

គ្រឿងសម្ភារៈសិក្សានានាដូចជាតុ ភ្លើងសម្រាប់សិក្សា និងធ្នើដាក់សៀវភៅ

ការទៅជួបគ្រូក្នុងកម្មវិធីជំនួបមាតាបិតា/គ្រូនៅពេលល្ងាចមួយក្នុងនាមមាតាបិតារបស់សិស្សនីមួយៗ។



## ទីតាំងនៅក្បែរឆ្នេរសមុទ្រយ៉ាងល្អអស្ចារ្យមួយ

វិទ្យាល័យ Mordialloc ស្ថិតនៅតំបន់ឆ្នេរសមុទ្រមួយស្អាត នៅប៉ែកអាគ្នេយ៍នៃក្រុងម៉ែលបិន។ បរិវេណសាលាស្ថិតនៅកន្លែងធម្មជាតិមួយក្បែរព្រៃក Mordialloc ជាប់និងឧទ្យានមួយចំនួនហើយនិងដីសើម។

រថភ្លើងនិងរថយន្តក្រុងផ្តល់សេវាដល់សាលាជាប្រចាំ - ការធ្វើដំណើរទៅក្រុងតាមរថភ្លើងស៊ីពេល 40 នាទី។

សាលានេះក៏នៅជិតហាងលក់ទំនិញនិងភោជនីយដ្ឋានយ៉ាងល្អ។ ហើយនិងមណ្ឌលហាងទំនិញដ៏ធំមួយឈ្មោះ Westfield Southland ផងដែរ។




## រឿងបានជោគជ័យថ្មីៗកន្លងមកនេះ

Fu (ហ្វ៊ូ) Roy (រ័យ) Zhu (ជូ) មកពីប្រទេសចិន បានរៀនភាសាអង់គ្លេសជាភាសាបន្ថែម គឺមីវិទ្យាគណិតវិទ្យាឯកទេស វិធីសាស្ត្រគណិត រូបវិទ្យា និងក្បួនដោះស្រាយបញ្ហានៅវិទ្យាល័យ Mordialloc ។

Roy ស្ថិតក្នុងចំណោមសិស្សកំពូលប្រាំនាក់នៃថ្នាក់ឆ្នាំ 2024 ដោយបានចំណាត់ថ្នាក់ ATAR 96.7 និងសព្វថ្ងៃកំពុងខំរៀនយកសញ្ញាបត្រគណិតវិទ្យានិងរូបវិទ្យានៅសាកលវិទ្យាល័យម៉ែលបិន។

"ពេលសិក្សារបស់ខ្ញុំនៅវិទ្យាល័យ Mordialloc ជាវគ្គមួយនៃជីវិតខ្ញុំដែលមិនអាចភ្លេចបាននិងពិតជាមានតម្លៃ។ បរិយាកាសដែលមានភាពកក់ក្តៅនិងរាក់ទាក់នៅអូស្ត្រាលីអនុញ្ញាតឱ្យខ្ញុំចូលដោយរលូន

ទៅក្នុងបរិស្ថានពហុប្បធម៌ ហើយនិងដោយសន្សឹមៗ ធ្វើតាមគេក្នុងសង្គមធំបាន។ ខ្ញុំនឹងមានអារម្មណ៍ល្អជានិច្ចអំពីមិត្តភក្តិដែលខ្ញុំបានបង្កើតនៅទីនោះ ហើយការណែនាំពីគ្រូនានារបស់ខ្ញុំនឹងបន្តដឹកនាំខ្ញុំតាមផ្លូវទៅភាពជោគជ័យ។"

Qianli (គាងលី) Charlie (ឆាលី) Guo (គួ) មកពីប្រទេសចិន បានសិក្សាភាសាអង់គ្លេសជាភាសាបន្ថែម (EAL) ភាសាជប៉ុន ភាសាចិន គីមីវិទ្យា វិធីសាស្ត្រគណិត គណិតវិទ្យាឯកទេស និងរូបវិទ្យានៅវិទ្យាល័យ Mordialloc ។

ឆាលី ជា DUX (សិស្សកំពូល) នាឆ្នាំ 2021 របស់សាលានេះ ដោយមានចំណាត់ថ្នាក់ ATAR 98.3 ហើយឥឡូវនេះកំពុងសិក្សាយកបរិញ្ញាបត្រខាងវិទ្យាសាស្ត្រនិងចិត្តសាស្ត្រនៅសាកលវិទ្យាល័យម៉ែលបិន។

"ការសិក្សានៅវិទ្យាល័យ Mordialloc គឺជាពេលដែលប្រណិតនិងធ្វើឱ្យមានការចងចាំក្នុងជីវិតរបស់ខ្ញុំ។ បរិយាកាសរាក់ទាក់អូស្ត្រាលីបានជួយខ្ញុំក្នុងការអោបក្រសោបវប្បធម៌ខុសគ្នាមួយ ហើយនឹងចូលរួមក្នុងសង្គមធំដោយងាយ។ ខ្ញុំនឹងនឹកឃើញគុណតម្លៃមិត្តភក្តិដែលខ្ញុំបានបង្កើតនៅវិទ្យាល័យ Mordialloc ជារៀងរហូត។ ឱវាទពីគ្រូនានានឹងបន្តតម្រែតម្រង់ខ្ញុំឱ្យនៅក្នុងគន្លងផ្លូវរបស់ខ្ញុំឆ្ពោះទៅកាន់ភាពជោគជ័យ។"




# ទំនាក់ទំនងមកសាលា

Mordialloc College

1 Station Street, Mordialloc, Victoria, 3195

ទូរសព្ទទំនាក់ទំនង៖ +61 3 9580 1184

នាយករង៖ ត្រេសស៊ី ប៊ែសទិន (Tracey Bastin)

អ្នកសម្របសម្រួលសិស្សអន្តរជាតិ៖ Qun Joan Mao

ទូរសព្ទ៖ +61 3 9580 1184

អ៊ីមែល៖ mordialloc.co@education.vic.gov.au

វិបសាយ៖ https://www.mcclellandcollege.vic.edu.au/

**Victorian Government Schools International Student Program**

200 Victoria Parade, East Melbourne VIC 3002

Tel: +61 3 7022 1000
Email: international@education.vic.gov.au
Web: www.study.vic.gov.au

Published by the International Education Division

Department of Education Melbourne August 2025
© State of Victoria (Department of Education) 2025

CRICOS Provider Name and Code: Department of Education, 00861K